# កម្មវិធីជំនួយថវិកាក្នុងគ្រាមានអាសន្ន
## សំណួរដែលសួរជាញឹកញាប់

## តើកម្មវិធីជំនួយថវិកាក្នុងគ្រាមានអាសន្នគឺជាអ្វី?

នាយកដ្ឋានសុខភាពសង្គមកំពុងដំនើរការទៅលើកម្មវិធីជំនួយថវិកាក្នុងគ្រាមានអាសន្នចាប់ផ្តើមថ្ងៃទី 17 មេសា 2020។ កម្មវិធីនេះមានគោលបំណងជួយបំពេញតំរូវការ ប្រជាជនវ៉ាស៊ុីងតោនមួយចំនួនក្នុងកំឡុងពេលមានអាសន្នដែលបណ្តាលមកពីខូវីដ-19។

## ហេតុអ្វីបានជាវាកើតឡើង?

ជាការឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺខូវីដ-19 រដ្ឋាភិបាលInslee បានប្រកាសអាសន្នគ្រប់ក្រុងទាំងអស់នៅក្នុងរដ្ឋវ៉ាស៊ុីងតោន។ ហេតុនេះហើយទើបDSHS ផ្តល់ជំនួយក្នុងគ្រាមានអាសន្ននេះទៅដល់ក្រុមគ្រួសារ និងបុគ្គលម្នាក់ៗដែលជាធម្មតាមិនអាចទទួលបានជំនួយថវិកា។

## តើខ្ញុំត្រូវដាក់ពាក្យយ៉ាងដូចម្តេច?

កម្មវិធីនេះទាមទារការសំភាសន៍តាមទូរស័ព្ទ។ អ្នកអាចដាក់ពាក្យសុំតាមរយៈ (មួយគ្រួសារមួយផ្ទះ)

- ដាក់ពាក្យតាមអនឡាញតាមរយៈវេបសាយ WashingtonConnection.org ហើយទូរស័ព្ទមកមណ្ឌលទំនាក់ទំនង 877-501-2233ដើម្បីបំពេញសំភាសន៍
- ទូរស័ព្ទទៅ877-501-2233 ដើម្បីបំពេញពាក្យ
- សូមជ្រាបថាមណ្ឌលទំនាក់ទំនងទូរស័ព្ទមានការ ហៅចូលច្រើន អ្នកអាចរង់ចាំយូរ។ ពេលវេលាដែលល្អបំផុតដើម្បីធ្វើការគេគឺមុនម៉ោង 11ព្រឹក។ ហើយពេលដែលរវល់បំផុតគឺម៉ោង 11ព្រឹក ដល់ម៉ោង 2រសៀល។

ពួកយើងអាចប្រាប់អោយដឹងថាអ្នកមានសិទ្ធអាចទទួលបានជំនួយក្នុងការសំភាសន៍តាមទូរស័ព្ទ។

## តើខ្ញុំអាចទទួលបានជំនួយញឹកញាប់ប៉ុណ្ណា?

កម្មវិធីនេះមានសំរាប់គ្រួសារ(មួយផ្ទះ) មួយខែក្នុងរយៈពេល12ខែ ក្នុងអំឡុងពេលរដ្ឋមានអាសន្ន។

## តើកម្មវិធីនេះមានរយៈពេលយូរប៉ុណ្ណា?

វាគឺជាកម្មវិធីបណ្តោះអាសន្នហើយនឹងបញ្ចប់នៅពេលដែលរដ្ឋមានអាសន្នចប់។

## ប្រសិនបើខ្ញុំមិនមានកូនរស់នៅជាមួយ តើខ្ញុំអាចទទួលថវិកាជំនួយពីDCAPដែរឬទេ?

អ្នកអាចទទួលថវិកាពីDCAP។

## តើខ្ញុំអាចទទួលបានDCAP និង ថវិកាផ្សេងទៀតក្នុងពេលតែមួយដែររឺទេ?

មិនអាចទេ DCAPជាកម្មវិធីផ្តល់ថវិកាតែមួយដងក្នុងមួយគ្រួសារដែលមិនបានទទួលបានថវិកាពីកម្មវិធី DSHSផ្សេងទៀតទេ៕

## តើកម្មវិធីនេះកំណត់ប្រាក់ចំនូលប៉ុន្មាន?

ប្រាក់ចំនូល(បន្ទាប់ពីកាត់រួច)សំរាប់ប្រាក់ចំនូលទាំងអស់រកបានក្នុងមួយខែគឺផ្អែកទៅលើចំនួនមនុស្សនៅក្នុងគ្រួសារ:

| ចំនួនមនុស្សក្នុងផ្ទះ | ប្រាក់ចំនូលបន្ទាប់ពីកាត់រួច |
|---|---|
| 1 | $363 |
| 2 | $459 |
| 3 | $569 |
| 4 | $670 |
| 5 | $772 |
| 6 | $877 |
| 7 | $1,013 |
| 8+ | $1,121 |

## តើកម្មវិធីនេះមានកំណត់ធនធានដែររឺទេ?

ក្នុងអំឡុងពេលមានអាសន្ន អ្នកដែលមានធនធានរហូតដល់$6,000 ត្រូវបានលើកលែង៕ តំលៃរថយន្តរហូតដល់$10,000 ក៏ត្រូវបានលើកលែងដែរ៕

## តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវមានក្នុងការសំភាសន៍?

ក្នុងពេលសំភាសន៍ ពួកយើងនឹងពិភាក្សាអំពីប្រាក់ចំនូលទាំងអស់ក្នុងមួយខែ ធនធានដែលមាន និងការចំនាយដែលអ្នកត្រូវការជំនួយ៕

## តើការចំនាយប្រភេទណាដែលខ្ញុំអាចទទួលជំនួយបាន?

DCAPរ៉ាប់រងលើប្រភេទតំរូវការមានដូចជា: ការស្នាក់នៅ ថ្លៃទឹកភ្លើង សំលៀកបំពាក់ ការថែរក្សាសុខភាពតិចតួច សំភារៈប្រើប្រាស់ក្នុងផ្ទះ និងថ្លៃដំនើរសំរាប់ទៅធ្វើការ៕ DCAP អាចផ្តល់អាហារប្រសិនបើអ្នកមិនមានសិទ្ធទទួលបានជំនួយជាអាហារ៕

Washington State Department of Social & Health Services

Transforming lives

## តើថវិកាខ្ពស់បំផុតដែលទទួលបានពីDCAPមានចំនួនប៉ុន្មាន?

ជំនួយដែលទទួលបានគឺអាស្រ័យទៅលើចំនួនមនុស្សក្នុងគ្រួសារ ប្រាក់ចំនូល និងតំរូវការ៕
ជំនួយខ្ពស់បំផុតមានដូចខាងក្រោម:

| ចំនួនមនុស្សក្នុងគ្រួសារ | ជំនួយថវិកាខ្ពស់បំផុត |
|---|---|
| 1 | $363 |
| 2 | $459 |
| 3 | $569 |
| 4 | $670 |
| 5 | $772 |
| 6 | $877 |
| 7 | $1,013 |
| 8+ | $1,121 |

## តើខ្ញុំទទួលបានជំនួយយ៉ាងដូចម្តេច?

ប្រសិនបើអ្នកត្រូវបានយល់ព្រមពីDCAP ជំនួយរបស់អ្នកនឹងទទួលបានតាមការផ្ទេរប្រាក់កាតEBT៕
ប្រសិនបើអ្នកមិនមានកាត ពួកយើងនឹងផ្ញើអោយ៕ កាតរបស់អ្នកនឹងត្រូវផ្ញើទៅតាមប៉ុស្តិ៍៕

## តើខ្ញុំត្រូវតែជាពលរដ្ឋអាមេរិករឺ? ចុះប្រសិនបើខ្ញុំមិនមានលេខ Social Security?

អ្នកមិនចាំបាច់ជាពលរដ្ឋអាមេរិក រឺឋានៈអន្តោប្រវេសន៍ជាក់លាក់ដើម្បីបាន DCAPទេ៕ ជំនួយថវិកាDCAP គឺមិនបូករួមជាមួយ public charge test៕អ្នកមិនចាំបាច់ផ្តល់លេខ Social Security ដើម្បីទទួលបានពី DCAP៕

## តើឯកសារអន្តោប្រវេសន៍របស់ខ្ញុំនឹងត្រូវបានចែករំលែកជាមួយសហព័ន្ធអន្តោប្រវេសន៍(សញ្ជាតិអាមេរិកនិងសេវាអន្តោប្រវេសន៍)ដែររឺទេ?

DSHSនឹងមិនបញ្ជាក់ឯកសារអន្តោប្រវេសន៍ជាមួយUSCISទេសំរាប់អ្នកដែលមានសិទ្ធទទួលបានDCAP៕បុគ្គលម្នាក់ៗ រឺគ្រួសារដែលអាចទទួល បានជំនួយថវិកា រឺម្ហូប នឹងមានប្រវត្តិរូបអន្តោប្រវេសន៍បញ្ជាក់ដោយDSHS តាមរយៈ SAVE system ក្នុងកុងត្រាជាមួយ USCIS៕